ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានគោលនយោបាយ

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# ទស្សនវិស័យនៃការត្រៀមខ្លួនដើម្បីប្រែក្លាយសាលាធនធានជាសាលារៀនជំនាន់ថ្មី៖ ករណីសិក្សាវិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង

ហួ កែវពិសិដ្ឋ*[១] ស៊ីន ភារ៉ា[២], រុន ដារ៉ា[៣], អ៊ុត កញ្ញា[៤], ស្រី កុត[៥], និង ម៉ា ប៊ុងឃី[៦]
*វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត ហេតុនេះបានជាប្រទេសនីមួយៗជានិច្ចកាលត្រូវការធនធានមនុស្សដែលមានចំណេះដឹង និងជំនាញប្រកបដោយសមត្ថភាពខ្ពស់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាកសាងសង្គមជាតិឱ្យបានរឹងមាំ។ ដើម្បីឆ្លើយតបនឹងទស្សនៈខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី ក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំទាំងមូល។ ជាក់ស្តែងសាលាធនធានមួយចំនួនបានក្លាយទៅជាសាលារៀនជំនាន់ថ្មី។ ចំណែកវិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង ក៏ជាសាលាធនធានមួយដែលបាននឹងកំពុងត្រៀមអភិវឌ្ឍខ្លួនទៅជាសាលារៀនជំនាន់ថ្មី ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីធ្វើការស្រាវជ្រាវបាន ក្រុមអ្នកស្រាវជ្រាវបានកំណត់ក្រុមគោលដៅ និងកំណត់ចំនួនសំណាកដែលត្រូវធ្វើការសម្ភាសសម្រាប់ក្រុមគោលដៅនីមួយៗ បន្ទាប់មកបង្កើតកម្រងសំណួរសម្រាប់ចុះសម្ភាសតាមគោលដៅដែលបានកំណត់។ ជាលទ្ធផលនៃការសិក្សា មតិភាគច្រើនបានគាំទ្រសាលាធនធាន ខូវ ប៊ុនស៊ុន ឱ្យប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី បើទោះបីមានមតិមួយចំនួនសម្តែងមិនយល់ស្របនឹងគោលណ៍

សាលារៀនជំនាន់ថ្មីក៏ដោយ។ សរុបមក អ្នកចូលរួមភាគច្រើនបានបញ្ចេញទស្សនៈគាំទ្រការប្រែក្លាយសាលាធនធានវិទ្យាល័យខូវ ប៊ុនស៊ុន ក្រចេះក្រុងជាសាលារៀនជំនាន់ថ្មី។

**អាគតដ្ឋាន៖** ហួ, ក., ស៊ីន, ភ., រុន, ដ., អ៊ុត, ក.,ស្រី, ភ., &ម៉ា, ប.(២០២២). ទស្សនវិស័យនៃការត្រៀមខ្លួនដើម្បីប្រែក្លាយសាលាធនធានជាសាលារៀនជំនាន់ថ្មី៖ ករណីសិក្សាវិទ្យាល័យខូវ ប៊ុនស៊ុន ក្រចេះក្រុង,*កាលិកបត្រអប់រំកម្ពុជា,៥(១)*, ១-១០។

## ១. សេចក្តីផ្តើម

ក្រោមការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការបណ្តុះបណ្តាធនធានមនុស្សផ្នែកវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សា ក្រសួងបានបង្កើតគោលនយោបាយមួយចំនួនដើម្បីគាំទ្រការពង្រឹងសេវាអប់រំប្រកបដោយគុណភាព ជាពិសេសផ្នែកវិទ្យាសាស្ត្រដូចជា គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៨) គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦) និងគោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦) ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅយុគសម័យឌីជីថលឬឧស្សាហកម្ម៤.០។ ក្រៅពីការបង្កើតគោលនយោបាយក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលក៏កំពុងយកចិត្តដាក់ខ្ពស់លើបច្ចេកវិទ្យាព័ត៌មាន ដោយបានបង្កើតគោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០(ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា, ២០១៩) និងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ (ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ២០២១)។

សាលាមធ្យមសិក្សាធនធានគឺជាសាលាដែលត្រូវបានយកចិត្តទុកដាក់ខ្ពស់លើការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើងជាដើម) ដើម្បីលើកស្ទួយការផ្តល់សេវាគុណភាពអប់រំផ្នែកវិទ្យាសាស្ត្រដល់សាលារៀន។ សាលាមធ្យមសិក្សាធនធាននឹងផ្តល់ការដឹកនាំ និងតម្រង់ទិសក្នុងការជួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ និងការប្រើប្រាស់វិធីសាស្ត្រថ្មីៗ ក្នុងការបង្រៀននិងរៀនដើម្បីគាំទ្រគោលយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាថ្មី។ យុទ្ធសាស្ត្របណ្តាញសាលាមធ្យមសិក្សាធនធានរួមមាន ការបណ្តុះវប្បធម៌ធ្វើការងារជាមួយគ្នា ដកបទពិសោធការងារពីគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នារវាងសាលារៀននានា និងសាលារៀនក្នុងបណ្តាញ ព្រមទាំងសហគមន៍

ឱ្យបានទូលំទូលាយ។ សាលារៀនក្នុងបណ្ដាញអាចប្រើប្រាស់សម្ភារៈរូបវន្តរបស់សាលាធនធានដែលជាស្នូលរបស់បណ្ដាញ។ ទោះបីជា សាលាមធ្យមសិក្សាធនធានមានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តជាច្រើន ដើម្បីគាំទ្រដល់ការអប់រំតាមបែបទំនើបយ៉ាងណាក៏ដោយ សាលាធនធាននៅតែមិនទាន់ឆ្លើយតបបានល្អទៅនឹងការរំពឹងទុកដូចសាលារៀនជំនាន់ថ្មី ទើបក្រសួងមានគម្រោងពង្រីកវិសាលភាពសាលាធនធានឱ្យប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដែលស្របទៅនឹងគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មីក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំ(គោលនយោបាយសាលាមធ្យមសិក្សាធនធាន, ២០០៨)។

គោលនយោបាយសាលារៀនជំនាន់ថ្មីបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមមាននៅកម្ពុជាក្នុងសតវត្សរ៍ទី ២១។ បញ្ហាប្រឈមទាំងនោះលេចចេញពីប្រភពជាច្រើនរួមមាន សមាហរណកម្មនៃសហគមន៍អាស៊ាន ការកើនឡើងនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជ្រាតចូលយ៉ាងឆាប់រហ័សនូវប្រព័ន្ធបច្ចេកវិទ្យានៅក្នុងសង្គមកម្ពុជា ការកើនឡើងផ្នែកនគរូបនីយកម្ម ការពង្រីកសាលារៀនឯកជន និងចំនួនពលរដ្ឋជាយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលតម្រូវឱ្យមានសេចក្តីណែនាំដ៏ទូលំទូលាយពីជម្រើស និងគំនិតប្រកួតប្រជែងនៅក្នុងពិភពលោកបច្ចុប្បន្ន។ សាលារៀនជំនាន់ថ្មីព្យាយាមបង្កើតគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់នឹងស្តង់ដាថ្មី ដោយមានគណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សរ៍ទី២១។ សាលារៀនជំនាន់ថ្មីមានគោលដៅបង្កើតសាលារៀនសាធារណៈស្វយ័តដែលគ្រប់គ្រងដោយវិន័យតឹងរឹងក្នុងការបំពេញភារកិច្ចនិងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់ កែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗ ដែលរួមបញ្ចូលការជ្រើសរើសគ្រូដោយការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ច ការបំប៉នសមត្ថភាពគ្រូបង្រៀនបន្ថែមលើផ្នែកបច្ចេកវិទ្យាអប់រំ វិធីសាស្ត្របង្រៀន STEM និងការសិក្សាឱ្យស្គាល់បញ្ហា និងការរកដំណោះស្រាយ ព្រមទាំងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននិងពង្រីកសេវាអប់រំសម្រាប់យុវជនកម្ពុជាដែលរួមបញ្ចូលទាំងសេវាប្រឹក្សាអាជីព សកម្មភាពសិក្សាប្លែកៗដូចជា ការងារគម្រោង ក្លឹបអ្នកសិក្សាតាមមុខវិជ្ជា ការសិក្សាតាមឧបករណ៍ចល័ត និងកម្មវិធីសិក្សាបំណិនជីវិត។ ដើម្បីសម្រេចបានគោលបំណង និងគោលដៅដែលបានកំណត់ ក្រសួងបានដាក់យុទ្ធសាស្ត្រសំខាន់ៗដូចជា ១) ជ្រើសរើសសាលារៀនគោលដៅយ៉ាងហ្មត់ចត់ដោយជ្រើសយកសាលាដែលមានសក្តានុពលពេញលេញក្នុងការវិនិយោគឱ្យមានប្រសិទ្ធភាពខ្ពស់ ២ ) កសាងភាពជាដៃគូជិតស្និទ្ធជាមួយតួអង្គមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីការអនុវត្តនិងជួយផ្តត់ផ្គង់ធនធានដល់សាលារៀនជំនាន់ថ្មី ៣) ជ្រើសរើសគណៈគ្រប់គ្រងសាលាតាមរយៈការប្រកួតប្រជែង ការលើកទឹកចិត្ត

ផ្សារភ្ជាប់នឹងការបំពេញភារកិច្ចបានល្អ ដើម្បីពង្រឹងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលារៀន ៤) ការផ្តល់ប្រាក់លើកទឹកចិត្ត ពិសេសដល់គ្រូបង្រៀនដើម្បីលើកកម្ពស់ការបំពេញភារកិច្ចឈានទៅលុបបំបាត់ការបង្រៀនឯកជនដល់សិស្សរបស់ខ្លួនដែលប៉ះពាល់ដល់វិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូរគ្រូបង្រៀន ៥) ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយ ដើម្បីជំរុញការច្នៃប្រឌិតថ្មីគឺសិស្សមិនត្រឹមតែទទួលបានការប្រើប្រាស់ឧបករណ៍រឹងប៉ុណ្ណោះទេ ពួកគេនឹងទទួលបានការប្រើកម្មវិធីទន់ក្នុងការអប់រំទំនើបទៀតផង (ឧទាហរណ៍ កម្មវិធី Literatu, 3D classroom។ល។) ៦) ការប្រកាន់ខ្ជាប់នៅម៉ោងបង្រៀនតាមសេចក្តីណែនាំផ្លូវការនិងបង្កើនម៉ោងរៀនរហូតដល់៣៦ ម៉ោង ក្នុងមួយសប្តាហ៍ នៅកម្រិតបឋមសិក្សា និង៤០ម៉ោងក្នុងមួយសប្តាហ៍សម្រាប់មធ្យមសិក្សា និង ៧) ការធ្វើទំនើបកម្មបរិស្ថានសិក្សា ដោយការប្រើគំនិតច្នៃប្រឌិតថ្មីក្នុងស្ថាបត្យកម្មអប់រំ ដើម្បីកែប្រែបន្ទប់រៀន និងបន្ទប់ផ្សេងទៀតឱ្យសម្របទៅនិងស្តង់ដាសាលារៀននាសតវត្សរ៍ទី ២១ (គោលនយោបាយសាលារៀនជំនាន់ថ្មី, ២០១៦)។

សព្វថ្ងៃនេះ ក្រសួងបាននិងកំពុងព្យាយាមប្រែក្លាយសាលាធនធានដែលមានស្រាប់នូវហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តទៅជាសាលារៀនជំនាន់ថ្មី។ វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង ជាសាលាធនធានមួយដែលបាននិងកំពុងប្រែក្លាយមុខមាត់ទៅជាសាលារៀនជំនាន់ថ្មីនាពេលខាងមុខ។ វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង មានទីតាំងនៅភូមិអូរឫស្សី២ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។ វិទ្យាល័យនេះបានកកើតតាំងពីសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៦៦មកម្ល៉េះ ហើយត្រូវបានដាក់ឈ្មោះថា អនុវិទ្យាល័យ ខូវ ប៊ុនស៊ុន ដែលកសាងឡើងដោយគហបតី ខូវ ប៊ុនស៊ុន។ នៅឆ្នាំ ១៩៧០-១៩៧៩ អនុវិទ្យាល័យ ខូវ ប៊ុនស៊ុន ត្រូវបានដាក់ជាមណ្ឌលកុមារ។ រហូតមកដល់ពេលនេះ ក្នុងការដឹកនាំ និងគ្រប់គ្រងវិទ្យាល័យដ៏ចំណាស់មួយនេះមានគណៈគ្រប់គ្រងចំនួន៤រូបមកហើយ ក្នុងនោះមានលោកនាយកទី១គឺ ស.ម ប៉ិច ផន នាយកទី២គឺ ស.ម សំ ស៊ា នាយកទី៣គឺ លោក នូ ផល្លុន នាយកទី៤គឺ លោក ហួ កែវពិសិដ្ឋ។ រហូតមកដល់ឆ្នាំ១៩៩៧ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីសម្តេចតេជោ ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានកសាងអគារចំនួន៣ ខ្នងស្មើនឹង ១០បន្ទប់។ នៅឆ្នាំ២០០៧ ធនាគារអភិវឌ្ឍអាស៊ី(ADB) បានសាងសង់អគារអន្តេវាសិកដ្ឋាននារីចំនួន០១ខ្នង ស្មើនឹ១៤បន្ទប់ និងនៅឆ្នាំ ២០១០ សាលាមានអគារធនធានចំនួន ០១ ខ្នង ស្មើនឹង ១៧ បន្ទប់ ដោយបំពាក់សម្ភារៈពិសោធន៍ សៀវភៅសម្រាប់ដាក់ក្នុងបណ្ណាល័យនិងកុំព្យូទ័រ។ បច្ចុប្បន្ន វិទ្យាល័យនេះមានគ្រូបង្រៀនសរុប ៦៧ នាក់ ស្រី ៣៦ នាក់ និងមានសិស្សសរុប ១២៤៦ នាក់ សិស្សស្រី ៦៧៨ នាក់ ដែលមានពីរកម្រិតសិក្សាគឺ មធ្យមសិក្សាបឋមភូមិ ថ្នាក់ទី ៧ ៨ ៩ មានសិស្សសរុប ៥២៣ នាក់ ស្រី ២៩៤ នាក់ និងមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ១១ ១២ មានសិស្សសរុប ៧២៣ នាក់ ស្រី ៣៨៤ នាក់។

***សំនួរស្រាវជ្រាវ៖*** តើវិទ្យាល័យខ្វរ ប៊ុនស៊ុន ក្រចេះក្រុងត្រូវត្រៀមខ្លួនរបៀបណា ដើម្បីប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី?

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមការងារធ្វើការជ្រើសរើសអ្នកផ្តល់សម្ភាសរួមមាន៖ លោកនាយក នាយករង គណៈកម្មការគ្រប់គ្រងសាលា គ្រូបង្រៀនបឋមភូមិ និងទុតិយភូមិ (ពីររូបក្នុងមួយកម្រិតថ្នាក់) អាណាព្យាបាលសិស្សដប់ពីររូបដែលមានកូនៗរៀននៅសាលានេះ ព្រមទាំងអាជ្ញាធរមូលដ្ឋាន។ អ្នកផ្តល់សម្ភាសទាំងអស់គឺស្ថិតនៅក្នុងមូលដ្ឋានផ្ទាល់។

ចំពោះដំណើរការស្រាវជ្រាវ ក្រុមអ្នកស្រាវជ្រាវបានប្រជុំពិភាក្សាគ្នាអំពីប្រធានបទដើម្បីឱ្យសមាជិកក្នុងក្រុមបានយល់ស៊ីជម្រៅ បន្ទាប់មកក្រុមការងារក៏បានប្រជុំនៅថ្ងៃបន្ទាប់ ដើម្បីបង្កើតសំណួរគន្លឹះ ក៏ដូចជាកម្រងសំណួរសម្រាប់សម្ភាស។ ក្រុមអ្នកស្រាវជ្រាវក៏បានសម្រេចចែកឱ្យសមាជិកក្រុមម្នាក់ៗបង្កើតសំណួរគន្លឹះទៅតាមក្រុមគោលដៅ ដែលបានជ្រើសរើស ដែលមានសមាជិកចំនួន ០៦ នាក់ ដោយចែកជា០៤ក្រុមគោលដៅ។

នៅពេលបង្កើតសំណួរគន្លឹះរួចរាល់ហើយ សមាជិកម្នាក់បានទូរស័ព្ទស្នើសុំអញ្ជើញគណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋាននិងលោកគ្រូ អ្នកគ្រូពាក់ព័ន្ធដើម្បីឱ្យក្រុមការងារស្រាវជ្រាវបានសម្ភាសពាក់ព័ន្ធនឹងប្រធានបទខាងលើ។ ថ្ងៃសម្ភាសន៍ ក្រុមការងារបានទៅដល់ទីតាំងគោលដៅរៀងៗខ្លួន រួចហើយសមាជិកនីមួយៗបានសុំអនុញ្ញាតពីអ្នកផ្តល់សម្ភាសដូចជា លោកនាយក គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល ដោយប្រាប់ពីមូលហេតុនិងគោលបំណងនៃការស្រាវជ្រាវអំពីប្រធានបទខាងលើ។ ក្រោយពីសមាជិកក្រុមបានជម្រាបនូវមូលហេតុនិងគោលបំណងរួចហើយ សមាជិកក្រុមបានធ្វើការសម្ភាសយកសំណាក តាមការបែងចែកខាងលើ។ រាល់ការសម្ភាសរបស់ក្រុមអ្នកស្រាវជ្រាវត្រូវបានកត់បញ្ចូលទៅក្នុងទម្រង់សម្រាប់បំពេញទិន្នន័យសម្ភាស និងថតជាខ្សែអាត់សំឡេង។

ក្នុងពេលប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវគោរពតាមគោការណ៍ក្រមសីកធម៌ស្រាវជ្រាវទាំង៥ចំណុច។ ក្រុមការងារពុំមានការបង្ខិតបង្ខំអ្នកផ្តល់សម្ភាសទេ ដោយប្រើគោលការណ៍ការស្ម័គ្រចិត្តក្នុងការផ្តល់សម្ភាសដល់ក្រុមការងារ ហើយក៏ពុំបានបង្ហាញឈ្មោះ អត្តសញ្ញាណ ឬក៏ទិន្នន័យទាំងឡាយណាដែលបានសម្ភាសពីអ្នកផ្តល់សម្ភាសជាសាធារណៈនោះឡើយ។ មួយវិញទៀត សមាជិករបស់ក្រុមការងារក៏ពុំបានកុហកឬក៏ប្រើល្បិចបោកបញ្ឆោតណាមួយ ដើម្បីបានមតិយោបល់ពីអ្នកផ្តល់សម្ភាសទេក្នុងនេះផងដែរ ប្រសិនបើអ្នកផ្តល់សម្ភាសលែងចង់ឱ្យសម្ភាស ក្រុមការងារក៏យល់ស្របតាម។ នៅក្នុង

ដំណើរការនៃការស្រាវជ្រាវនេះ ផលវិបាកដែលក្រុមការងារទទួលបាននោះគឺ ការយល់ដឹងពីគោលការណ៍សាលាជំនាន់ថ្មីរបស់លោកគ្រូអ្នកគ្រូ និងអាណាព្យាបាលនៅមានកម្រិតនៅឡើយ។

## ៣. លទ្ធផលស្រាវជ្រាវ

ក្រោយពីការសិក្សាវិភាគលើសំណាកដែលបានមកពីការសម្ភាស ការស្រាវជ្រាវបង្ហាញថា មានមតិយោបល់ជាច្រើនចំពោះការត្រៀមខ្លួន ដើម្បីប្រែក្លាយសាលាធនធានវិទ្យាល័យខ្វរ ប៊ុនស៊ុន ក្រចេះក្រុងជាសាលារៀនជំនាន់ថ្មី។ ខាងក្រោមជាមតិយោបល់ដែលបញ្ជាក់យ៉ាងលម្អិតចេញពីថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងសាលា ព្រមទាំងអាណាព្យាបាលផ្ទាល់ដើម្បីត្រៀមខ្លួននិងផ្តល់ការគាំទ្រក្នុងការប្រែក្លាយពីសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី៖

### ក. ទស្សនៈយល់ឃើញរបស់នាយក នាយិកា

យោងតាមការសម្ភាសចេញពីលោកនាយក នាយករងមានប្រសាសន៍ថា លោកគាំទ្រក្នុងការប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី ដោយលោកយល់ថា សាលាជំនាន់ថ្មីអាចលើកកម្ពស់គុណភាពសិក្សារបស់សិស្សឱ្យកាន់តែល្អប្រសើរនិងដើរទាន់សភាពការណ៍ពិភពលោក។ លោកបន្តថា ធនធានដែលសាលាកំពុងមានបច្ចុប្បន្នគឺពុំអាចគាំទ្រដល់ការបង្រៀន តាមគោលនយោបាយសាលារៀនជំនាន់ថ្មីនៅឡើយទេ ពីព្រោះនៅសាលាលោកគ្រប់គ្រងសព្វថ្ងៃនៅខ្វះទាំងធនធានគ្រូបង្រៀននិងសម្ភារៈរូបវន្តជាច្រើនទៀត។ ធនធានគ្រូបង្រៀននៅមានកម្រិត គ្រូកម្រិតទុតិយភូមិមិនគ្រប់ទៅតាមឯកទេស និងកម្រិតថ្នាក់ ហើយគ្រូកម្រិតបឋមភូមិទៅជួយបង្រៀននៅថ្នាក់ទុតិយភូមិ។ ម្យ៉ាងទៀត ពួកគាត់នៅខ្វះការស្រាវជ្រាវបន្ថែម ជាពិសេសគ្រូបង្រៀនមួយចំនួនពុំទាន់មានការវិវត្តផ្នែកបំណិនឌីជីថល និងភាសាអង់គ្លេសនោះទេ។ ចំណែក សម្ភារៈរូបវន្តនៅសាលាសព្វថ្ងៃមិនទាន់បំពេញតម្រូវការការបង្រៀននិងរៀនបានទេ ឧទាហរណ៍ សព្វថ្ងៃក្នុងមួយបន្ទប់មានសិស្ស ៥០ នាក់ទៅ ៦០ នាក់ សិស្សពិបាកធ្វើការងារក្រុម ដោយសារតុវែងពេកពិបាកបំលាស់ទី កុំព្យូទ័រ ស្លាយ (LED projector) សម្ភារៈឧបទេស និងធនធានថវិកាសម្រាប់ទ្រទ្រង់ដំណើរការ។ លើសពីនេះទៅទៀត ពួកគាត់ក៏នៅមានកង្វល់ចំពោះបញ្ហាដែលតម្រូវឱ្យអាណាព្យាបាលផ្តល់ជាបដិភាគមួយចំនួន សម្រាប់គាំទ្រដំណើរការសិក្សារបស់កូនដោយសារតែសិស្សមួយចំនួនធំមកពីគ្រួសារដែលមានជីវភាពខ្វះខាត។

ជាចុងក្រោយលោកនាយក និងនាយករងមានការប្តេជ្ញាចិត្តថា នឹងខិតខំដឹកនាំគ្រប់គ្រងឱ្យដំណើរការបានល្អប្រសើរទាំងការងាររៀន និងបង្រៀន ព្រមទាំងជំរុញសិស្សឱ្យខិតខំវិវត្តខ្លួនដើម្បីទទួលបានលទ្ធផលសិក្សាល្អទាំងអស់គ្នា។

### ខ. ទស្សនៈយល់ឃើញរបស់លោកគ្រូ អ្នកគ្រូ

យោងតាមការសម្ភាស លោកគ្រូ អ្នកគ្រូមួយចំនួនធំមានប្រសាសន៍ថា ពួកគាត់គាំទ្រក្នុងការប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី ដោយយល់ឃើញថា សាលារៀនជំនាន់ថ្មីនឹងអាចលើកកម្ពស់គុណភាពសិក្សារបស់សិស្ស និងគុណភាពបង្រៀនរបស់គ្រូឱ្យកាន់តែល្អប្រសើរ ដើម្បីដើរឱ្យទាន់សភាពការណ៍ពិភពលោក។ ក្នុងន័យនេះ ពួកគាត់បានបញ្ជាក់ច្បាស់ៗថា សាលារៀនជំនាន់ថ្មីនឹងជំរុញឱ្យមានការស្រាវជ្រាវ ការបង្កើតការសិក្សា ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាប្រចាំ មានវិន័យតឹងរឹង មានសម្ភារៈបច្ចេកវិទ្យាទំនើបៗសម្រាប់គាំទ្រដល់ការបង្រៀននិងរៀននៅសតវត្សន៍ទី២១។ លើសពីនេះទៅទៀត ការជ្រើសរើសគ្រូមកបង្រៀននិងសិស្សមករៀននៅសាលារៀនជំនាន់ថ្មី ត្រូវបានឆ្លងកាត់ការដាក់ពាក្យប្រឡង និងសម្ភាសប្រកបដោយភាពសុក្រឹតនិងយុត្តិធម៌ដែលសបញ្ជាក់ឱ្យឃើញថាសាលារៀនបានផ្តល់ឱកាសឱ្យមានការប្រកួតប្រជែងយ៉ាងទូលំទូលាយ។

លោកគ្រូ អ្នកគ្រូ ក៏មានយោបល់ប្រហាក់ប្រហែលទៅនឹងលោកនាយកដែរ ចំពោះធនធានសម្ភារៈរបស់សាលារៀននាពេលបច្ចុប្បន្ន គឺពុំអាចគាំទ្រដល់ការបង្រៀននៅពេលក្លាយជាសាលារៀនជំនាន់ថ្មីនៅឡើយទេ ពីព្រោះសម្ភារៈរូបវន្តនៅសាលាសព្វថ្ងៃ ពុំទាន់បំពេញតម្រូវការការបង្រៀននិងរៀនបានទេ ក៏គាត់បានបង្ហាញក្តីព្រួយបារម្ភអំពីសមត្ថភាពគ្រូបង្រៀនទៅលើការស្រាវជ្រាវនិងការប្រើប្រាស់បច្ចេកទេសទំនើប ក៏ដូចជាការចូលរួមពីឪពុកម្តាយរបស់សិស្សក្នុងការបង់ថ្លៃសិក្សា។

ផ្ទុយទៅវិញ សម្រាប់គ្រូបង្រៀនដែលមានវ័យចំណាស់មួយចំនួនមិនគាំទ្រឱ្យប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មីនោះទេ ដោយសារពួកគាត់មានសុខភាពមិនរឹងមាំ មិនអាចអភិវឌ្ឍសមត្ថភាពបន្ថែម មិនមានពេលស្រាវជ្រាវនិងមិនមានចំណេះដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យា។ ឯសិស្សវិញត្រូវរៀនច្រើនមិនមានពេលវេលាសម្រាកគ្រប់គ្រាន់ មិនមានពេលស្រាវជ្រាវជាប្រចាំ កិច្ចការសាលាច្រើនមានការប្រកួតប្រជែកខ្លាំង ដែលធ្វើឱ្យសិស្សខ្សោយ មានសម្ពាធ និងចង់បោះបង់ការសិក្សា។ លោកគ្រូអ្នកគ្រូក៏មានយោបល់ស្រដៀងទៅនឹងលោកនាយករងដែរថា សិស្សភាគច្រើនជាសិស្សដែលមកពីតាមបណ្តាលស្រុកដែលមានជីវភាពខ្វះខាតនាំឱ្យមានការលំបាកដល់អាណាព្យាបាលសិស្សទាំងនោះ។

### គ. ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា

គណៈកម្មាការគ្រប់គ្រងសាលាបានមានប្រសាសន៍ថា លោកគាំទ្រឱ្យសាលា ខូវ ប៊ុន ស៊ុន ក្រចេះក្រុង ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដោយសារលោកចង់បានគុណភាពអប់រំល្អ ទាំងការរៀននិងបង្រៀន។ សិស្សទទួលបាននូវសិទ្ធិអប់រំស្មើៗគ្នា វាក៏មានលក្ខណៈល្អប្រសើរ ដោយមានការចូលរួមនិងទទួលខុសត្រូវពីសហគមន៍។ ចំពោះឪពុកម្តាយ ឬអាណាព្យាបាលសិស្សមានទំនាក់ទំនងល្អជាមួយសាលារៀនផងដែរ។

**ឃ. ទស្សនៈយល់ឃើញរបស់អាណាព្យាបាល**

ឆ្លងតាមការសម្ភាសអាណាព្យាបាលមួយចំនួនចង់ឱ្យសាលាធនធាន ខូវ ប៊ុនស៊ុន ក្រចេះក្រុង ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី។

អាណាព្យាបាលបានលើកឡើងថា«សាលារៀនជំនាន់ថ្មីនឹងធ្វើឱ្យកូនរបស់ពួកគាត់មានពេលវេលារៀនសូត្រគ្រប់គ្រាន់ ចេះស្រាវជ្រាវ ចេះគិតដោយខ្លួនឯង ចេះស្វ័យសិក្សាបានជិតដល់ រៀនសូត្របានទៀងទាត់ មានការប្រកួតប្រជែងគ្នាទៅវិញទៅមក។ ការបង្រៀនតាមបែបទំនើប បំពាក់ដោយប្រព័ន្ធបច្ចេកវិទ្យាទំនើប»។ អាណាព្យាបាលម្នាក់ទៀតបានមានប្រសាសន៍ថា «កូនរបស់គាត់មិនតម្រូវឱ្យរៀនគួរបន្ថែមរហូតដល់ពេលយប់ទេដែលធ្វើឱ្យគាត់មានការព្រួយបារម្ភជាខ្លាំង» ជាការពិតណាស់ការរៀនគួរបន្ថែមមិនថា ពេលថ្ងៃ ឬពេលយប់ វាអាចបង្កជាអសន្តិសុខ អសុវត្ថិភាព អាណាធិបតេយ្យភាព គ្មានសណ្តាប់ធ្នាប់ ពុំមានសុវត្ថិភាពពេលធ្វើចរាចរណ៍ បង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗ បង្កឱកាសឱ្យក្មេងទំនើងបង្កើតភាពចលាចលនិងបណ្តាលឱ្យមានឱកាសសេពគ្រឿងញៀននិងគ្រឿងស្រវឹងជាដើម។

ចំណែកឯការសិក្សាដែលមានពេលវេលាសម្រាកគ្រប់គ្រាន់ មានគ្រូបង្រៀនល្អ និងសិស្សគោរពពេលវេលាបានច្បាស់លាស់ មានការពង្រឹងពេលវេលារៀននិងបង្រៀន មានវិន័យតឹងរឹងធ្វើឱ្យមានគុណភាពក្នុងការបង្រៀននិងរៀន។ សាលារៀនជំនាន់ថ្មីជាសាលាដែលមានបរិស្ថានស្អាត មានសណ្តាប់ធ្នាប់ មានវិន័យ មានអគារសិក្សាស្អាត និងបរិយាកាសរីករាយដែលធ្វើឱ្យការរៀនសូត្ររបស់សិស្សមានមិនភាពធុញទ្រាន់។ ម្យ៉ាងវិញទៀត មានសមធម៌ចំពោះសិស្សដែលមានជីវភាពក្រីក្រ មធ្យមនិងខ្ពស់។ ចំណែកគ្រូបង្រៀនវិញទទួលបានប្រាក់លើកទឹកចិត្តស្មើៗគ្នា ដែលនាំឱ្យគ្រូបង្រៀនមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀនដូចគ្នានិងសិស្សផងដែរ ព្រមទាំងសម្រាលដល់ការចំណាយរបស់ពួកគាត់។

ទន្ទឹមនឹងនេះ ក៏មានឪពុកម្តាយនិងអាណាព្យាបាលមួយចំនួនមិនគាំទ្រឱ្យសាលាធនធាន ខូវ ប៊ុនស៊ុន ក្រចេះក្រុងប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មីនោះទេ ដោយពួកគាត់បានលើកឡើងថា «កូនរបស់គាត់អត់បានរៀនគួរបន្ថែម បណ្តាលឱ្យកូនៗរបស់ពួកគាត់ខ្ជិលរៀននិងស្រាវជ្រាវ ធ្វើឱ្យកូនរបស់គាត់ខ្សោយគ្រូៗមិនយកចិត្តទុកដាក់ក្នុងការបង្រៀនដូចពេលរៀនគួរ» អាណាព្យាបាលខ្លះទៀតបាននិយាយថា «សិស្សមានពេលទំនេរច្រើនលេងទូរស័ព្ទ ដើរលេង អត់ខំប្រឹងរៀន សិស្សមិនសូវឱ្យតម្លៃលើកការសិក្សារៀនសូត្រ»។ ម្យ៉ាងទៀត សាលារដ្ឋត្រូវតម្រូវឱ្យសិស្សបង់បដិភាគដូចសាលាឯកជនដែរ ដែលត្រូវចំណាយថវិកាច្រើនលើការសិក្សារបស់កូនៗ។

## ៤. សេចក្តីសន្និដ្ឋាន

ក្រោយពីក្រុមអ្នកស្រាវជ្រាវធ្វើការវិភាគរួចមក លទ្ធផលស្រាវជ្រាវបានថា មតិមួយចំនួនបានគាំទ្រសាលាធនធានខូវ ប៊ុនស៊ុន ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដោយសារសាលារៀនជំនាន់ថ្មីផ្តល់ការអប់រំប្រកបដោយគុណភាព ពង្រឹងសមត្ថភាពបង្រៀននិងរៀន មានវិន័យតឹងរឹង មានសន្តិសុខសុវត្ថិភាព កាត់បន្ថយការបង្រៀន និងរៀនឯកជនដែលនាំឱ្យកាត់ការចំណាយរបស់អាណាព្យាបាល។ គ្រូបង្រៀន និងសិស្សមានទំនាក់ទំនងល្អ មានសាមគ្គីភាពល្អក្នុងការសិក្សាស្រាវជ្រាវអ្វីដែលថ្មី បង្កើតថ្មីស្របទៅនឹងបរិបទថ្មី។ ទន្ទឹមនឹងការគាំទ្រក៏មានមតិមួយចំនួនលើកឡើងថា សមត្ថភាពគ្រូបង្រៀននៅមានកម្រិត លទ្ធផលសិក្សាមិនដូចការរំពឹងទុកនោះទេ សិស្សរៀនច្រើនគ្មានពេលសម្រាក មានការប្រកួតប្រជែងខ្លាំងបណ្តាលឱ្យសិស្សខ្សោយនិងមានសម្ពាធរហូតចង់បោះបង់ការសិក្សា។ សរុបមក ឆ្លងតាមការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់អំពីសាលារៀនជំនាន់ថ្មី ដែលជានាស្តង់ដាខ្ពស់នៃអភិបាលកិច្ចល្អដូចជា តម្លាភាព គណនេយ្យភាពនិងការចូលរួមបង្កើតបានជាកម្លាំងទាក់ទាញវិនិយោគថ្មីៗក្នុងវិស័យអប់រំដែលនាំឱ្យគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាណាព្យាបាលសិស្ស ភាគច្រើនមានបំណងឱ្យសាលាខូវ ប៊ុនស៊ុន ទៅជាសាលារៀនជំនាន់ថ្មីក្នុងពេលឆាប់ៗ។

### អនុសាសន៍

បន្ទាប់ពីបានចុះសិក្សាជ្រាវស្រាវរួចមក ក្រុមអ្នកស្រាវជ្រាវផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីឱ្យសាលាធនធានអាចប្រែក្លាយជាសាលារៀនជំនាន់ថ្មីបាន លុះត្រាតែមានការគាំទ្របន្ថែមផ្នែកធនធានសម្ភារៈ និងធនធានមនុស្ស ដូចខាងក្រោម៖

- ធនធានសម្ភារៈ៖ សាលាត្រូវការអគារសិក្សាបន្ថែម បន្ទប់ប្រកបដោយផាសុកភាព និងមានបំពាក់ដោយបច្ចេកវិទ្យាទំនើប តុដែលអាចបម្លាស់ទីបាន។ល។
- ធនធានមនុស្ស៖ សាលាត្រូវការគណៈគ្រប់គ្រងប្រកបដោយគុណវុឌ្ឍិ លោកគ្រូ អ្នកគ្រូមានវិជ្ជាជីវៈច្បាស់លាស់ ត្រូវចេះបំណិនឌីជីថល និងមានការអភិវឌ្ឍខ្លួនជាប្រចាំ។
- កិច្ចសហប្រតិបត្តិការៈ បង្កើតជាបណ្តាញសាលាជាមួយសាលារៀនជំនាន់ថ្មីដែលកំពុងមានប្រជាប្រិយភាពដើម្បីអាចរៀនសូត្រពីគ្នាទៅវិញទៅមក។

## សេចក្តីថ្លែងអំណរគុណ

*ក្រុមអ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណនាយកដ្ឋានគោលនយោបាយដែលបានចុះគាំទ្រការបណ្តុះបណ្តាលការស្រាវជ្រាវប្រតិបត្តិ និងបានដឹកនាំសម្របសម្រួលការសរសេរអត្ថបទស្រាវជ្រាវនេះ*

*ឡើង។ ក្រុមស្រាវជ្រាវក៏សូមថ្លែងអំណរគុណធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានគាំទ្រថវិកាលើការស្រាវជ្រាវមួយនេះ។*

## ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៨). គោលនយោបាយស្តីពី សាលាមធ្យមសិក្សាធនធាន. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). គោលនយោបាយស្តីពី សាលារៀនជំនាន់ថ្មី. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦(. គោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០. ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

រាជរដ្ឋាភិបាលកម្ពុជា.(២០២១). ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍